**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Aug-2015, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿង ឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តតាមាក់**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណី**
**ទាំងអស់នៃសំណុំរឿង០០៤**

**សហមេធាវី សោ អាន**
មុំ លុជ្ស
Göran SLUITER
Richard ROGERS

**សហមេធាវី អ៊ឹម ចែម**
ប៊ិត សៀងលឹម
John R.W.D. JONES QC

# ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ

១. ដោយអនុលោមតាមវិធាន ៥៥(២) និង ៥៥(៣)[1] នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") នៅពេលនេះ សូមធ្វើការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥[2]។

២. នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សចសអ ជូនដំណឹងដល់សហព្រះរាជអាជ្ញាថាកិច្ចស៊ើបសួរដែលកំពុងបន្តធ្វើនៅក្នុងសំណុំរឿង០០៤ បានចេញជាលទ្ធផលនៅក្នុងភស្តុតាងដែលថា វត្តតាមាក់ត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរឃុំឃាំងបណ្តោះអាសន្នមួយសម្រាប់ជនរងគ្រោះនៃការបោសសម្អាតភូមិភាគកណ្តាល និងអ្នកទោសនៅតាមផ្លូវ (prisoners en route) ឆ្ពោះទៅកាន់មន្ទីរសន្តិសុខដទៃទៀត[3] និងនៅក្នុងករណីខ្លះទៀតធ្វើជាទីកន្លែងសម្លាប់មនុស្ស[4]។ គាត់ជូនដំណឹងដល់សហព្រះរាជអាជ្ញា បន្ថែមទៀតថាមានភស្តុតាងអំពីទំនាក់ទំនងរបស់ អោ អាន ជាមួយនឹង វត្តតាមាក់ ដែលអាចនឹង មានការពាក់ព័ន្ធទៅនឹងការដឹងឮ និងការចូលរួមចំណែក របស់គាត់នៅក្នុងឧក្រិដ្ឋកម្មនានាដែលបាន ប្រព្រឹត្តនៅឯទីកន្លែងនោះ[5]។ ដោយសារតែវត្តតាមាក់មិនមែនជាទីកន្លែងមួយក្នុងចំណោមទីកន្លែងនានាដែលមានឈ្មោះយ៉ាងច្បាស់លាស់ ដែលបានកំណត់អត្តសញ្ញាណសម្រាប់ធ្វើការស៊ើបសួរជា "ទីតាំងឧក្រិដ្ឋកម្ម" យ៉ាងពេញលេញ សចសអ បានសុំឲ្យសហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីវិសាលភាពនៃកិច្ចស៊ើបសួរដែលត្រូវបានអនុញ្ញាតឲ្យធ្វើសម្រាប់ទីកន្លែងនោះ[6]។

៣. ដោយបានពិចារណាលើភស្តុតាងដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ សពអ សូមជូនដំណឹងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") ឲ្យបានជ្រាបថា សូមឲ្យទទួលយក និងអនុញ្ញាតឲ្យមានការស៊ើបសួរយ៉ាងពេញលេញលើឧក្រិដ្ឋកម្មនានាដែលអាចត្រូវបានប្រព្រឹត្តនៅទីកន្លែងវត្តតាមាក់ ក្នុងអំឡុងពេលដែល អោ អាន បានបម្រើការងារជាលេខាតំបន់៤១ នៃភូមិភាគកណ្តាល(អតីតភូមិភាគឧត្តរ)។ សពអ យល់ឃើញថាអង្គហេតុទាំងឡាយដែលពាក់ព័ន្ធ

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩), វិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន")។

[2] **D254** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ៦ កក្កដា ២០១៥។

[3] **D254** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, កថាខណ្ឌ ៨, ១០។

[4] **D254** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, កថាខណ្ឌ ១២។

[5] **D254** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, កថាខណ្ឌ ៩-១១។

[6] **D254** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, កថាខណ្ឌ ១៤-១៥, ១៧ក។

ទៅនឹងវត្តតាមាក់ គឺស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរនាពេលបច្ចុប្បន្ននេះ ដោយអាស្រ័យនូវការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដូចតទៅនេះ៖

ក) នៅក្នុងអំឡុងពេលនៃការបោសសម្អាតភូមិភាគកណ្តាល ដែលបានធ្វើឡើងដោយកម្មាភិបាលភូមិភាគនិរតី ក្រោមបញ្ជារបស់ អោ អាន កម្មាភិបាលមូលដ្ឋានរបស់ បកក និងគ្រួសាររបស់ពួកគេត្រូវបានចាប់ខ្លួន និងប្រហារជីវិតចោលនៅ ស-២១ និង នៅ *គុកដទៃទៀត*[7]។

ខ) ជនរងគ្រោះពីការបោសសម្អាតដែលបានធ្វើឡើងដោយ អោ អាន និង កម្មាភិបាលភូមិភាគនិរតី ក៏មានរួមបញ្ចូលផងដែរនូវប្រជាជនថ្មី ប្រជាជនដែលមានទំនាក់ទំនងទៅនឹងរបបមុន និង ប្រជាជនចាម។ មន្ទីរសន្តិសុខ គុក និង ទីកន្លែងសម្លាប់មនុស្ស ដែលមានចែងនៅក្នុងកថាខណ្ឌ ២៣-៥៣ គឺជា *ទីកន្លែងឧក្រិដ្ឋកម្មមួយចំនួន* ដែលនៅទីនោះបុគ្គលទាំងនេះត្រូវបានឃុំឃាំង និងត្រូវបានប្រហារជីវិតចោល[8]។

គ) អោ អាន ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមន្ទីរសន្តិសុខចំនួន ២៥ ដែលគេបានដឹងថាមានទីតាំងនៅក្នុងភូមិភាគកណ្តាល រួមទាំងវត្តតាមាក់ផង ដែលមានទីតាំងនៅឃុំជ្រៃវៀន ក្នុងស្រុកព្រៃឈរ[9]។ នៅក្នុងអំឡុងពេលនៃការកាន់កាប់របស់គាត់ជាលេខាតំបន់ ៤១ និងជាអនុលេខាភូមិភាគកណ្តាល មន្ទីរធំរបស់ អោ អាន មានទីតាំងនៅឃុំជ្រៃវៀន ក្នុងស្រុកព្រៃឈរ[10]។

ឃ) វត្តតាមាក់ គឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន ដែលត្រូវបានប្រើប្រាស់ដើម្បីឃុំពួកអ្នកទោស មុននឹងត្រូវបញ្ជូនទៅសម្លាប់នៅកន្លែងផ្សេងៗទៀតដែល អោ អាន បានទៅធ្វើទស្សនកិច្ច[11]។

---

[7] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣"), កថាខណ្ឌ ១៨-២១ (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។

[8] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣, កថាខណ្ឌ ២២ (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។

[9] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣, កថាខណ្ឌ ៨៧ និង ជើងទំព័រលេខ ៣៦២ ដោយលើកឡើងពី **D1.3.32.1** បញ្ជីឈ្មោះអ្នកទោសរបស់ DC-Cam, ២៣ សីហា ២០០៦, ERN (En) 00194822។ វត្តតាមាក់ មាននៅក្នុងបញ្ជី ត្រង់លេខរៀងទី ៣៦។

[10] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣, កថាខណ្ឌ ៨៨។

[11] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣, កថាខណ្ឌ ៩០(ច) និង ជើងទំព័រលេខ ៣៨៨។

ង) អោ អាន បានធ្វើផែនការ បានបញ្ជា និង បានអនុញ្ញាតឱ្យមានការចាប់ខ្លួន និងឃុំខ្លួនបុគ្គលនៅក្នុងតំបន់៤១ និងនៅភូមិភាគកណ្តាល ហើយនិងចលនារបស់ពួកអ្នកទោសរវាងស្រុកខុសៗគ្នា នៅក្នុងតំបន់៤១[12]។

៤. សពអ ពិចារណាថា ភ័ស្តុតាងដែលបានទទួលបច្ចុប្បន្នទាក់ទងនឹងការសម្លាប់កម្មាភិបាលភូមិភាគបូព៌ានៅ វត្តតាមាក់ ក៏អាចស្ថិតនៅក្នុងអង្គហេតុ និងឧក្រិដ្ឋកម្មដែល កសចស បានទទួលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីផងដែរ[13]។ បន្ថែមលើការចោទប្រកាន់ផ្សេងទៀតទាក់ទងនឹង វត្តតាមាក់ ដែលបានលើកឡើងខាងលើ កសចស ត្រូវបានផ្តល់សិទ្ធិអំណាចឱ្យស៊ើបសួរអំពីការសម្លាប់មនុស្ស ដែលដឹកដោយឡានពីភូមិភាគបូព៌ាទៅកាន់មន្ទីរសន្តិសុខ វត្តបាធាយ ក្នុងអំឡុងពេលឆ្នាំ១៩៧៨ ក្នុងតំបន់៤១ នៃភូមិភាគកណ្តាល[14]។ ការសម្លាប់កម្មាភិបាលភូមិភាគបូព៌ានៅ វត្តតាមាក់ ដែលបានរៀបរាប់នេះ ក៏អាចមានទំនាក់ទំនង និងជាផ្នែកនៃការសម្លាប់ដូចគ្នាដែលបានធ្វើឡើងនៅ វត្តបាធាយ។ ទោះជាយ៉ាងណា ដើម្បីចៀសវាងភាពមិនច្បាស់លាស់ណាមួយលើបញ្ហានេះ និងដើម្បីធានាថា កសចស ទទួលបានការអនុញ្ញាតិពេញលេញដើម្បីធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តឡើងនៅ វត្តតាមាក់ ដែលជាកន្លែង អោ អាន អាចទទួលខុសត្រូវនោះ ហេតុដូច្នេះ សពអ ផ្តល់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមខាងក្រោម ស្របតាមវិធាន ៥៣ និង ៥៥(៣) នៃវិធានផ្ទៃក្នុង។

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

៥. វត្តតាមាក់ ស្ថិតនៅក្នុងឃុំជ្រៃវៀន ស្រុកព្រៃឈរ (ជាផ្នែកមួយនៃតំបន់ ៤១ នៃភូមិភាគកណ្តាល) និងត្រូវបានប្រើប្រាស់ជាមន្ទីរថ្នាក់តំបន់ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ[15]។ ក្នុងចំណោមមុខងារផ្សេងៗ វត្តតាមាក់ ត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំងបណ្តោះអាសន្នដើម្បីដាក់

---

[12] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣, កថាខណ្ឌ ៩០(ង)។

[13] សចសអ បានស្នើសុំការបញ្ជាក់ថាតើការសម្លាប់កម្មាភិបាលភូមិភាគបូព៌ានៅ វត្តតាមាក់ បង្កើតបានជា "អង្គហេតុថ្មី" ដែលរារាំងមិនឱ្យមានការស៊ើបសួរដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរឬទេ។ សូមមើល **D254** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ១៧ ខ។

[14] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ កថាខណ្ឌ២៦។

[15] **D219/327** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង គុល ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ត្រង់ A3, A5។ **D219/217** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ធេន ហាម ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ត្រង់ A175-A177។

អ្នកទោសដែលត្រូវបញ្ជូនទៅកាន់មន្ទីរសន្តិសុខផ្សេងៗទៀត ឬទីតាំងសម្លាប់នានា ដោយរួមមាន កម្មាភិបាលមូលដ្ឋានរបស់ ប.ក.ក ដែលត្រូវបានបោសសម្អាតដោយកងកម្លាំងភូមិភាគនិរតី ដែលដឹកនាំដោយ អោ អាន[16]។ ក្នុងករណីខ្លះ កម្មាភិបាលត្រូវបានកោះហៅដោយមន្ទីរតំបន់ ៤១ ឲ្យមកចូលរួមវគ្គសិក្សានៅ វត្តតាមាក់ ដែលជាកន្លែងពួកគេត្រូវបានចាប់ខ្លួន ហើយបន្ទាប់មកបានបាត់ខ្លួន[17]។ ក្នុងករណីផ្សេងទៀត អ្នកទោសត្រូវបាននាំមកកាន់ វត្តតាមាក់ តាមឡានជាច្រើន ដែលក្នុងមួយឡានៗមានផ្ទុកមនុស្សពី៥០ ទៅ៦០នាក់[18]។ វត្តតាមាក់ ក៏អាចជាទីតាំងមួយ ក្នុងចំណោមទីតាំងទាំងឡាយដែលប្រជាជនមកពីភូមិភាគបូព៌ាត្រូវបានបញ្ជូនតាមឡានមកដាក់ និងសម្លាប់នៅរយៈពេលចាប់ពីឆ្នាំ១៩៧៧ ដល់១៩៧៨ ផងដែរ[19]។

៦. វត្តតាមាក់ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ លេខាតំបន់ ៤១ អោ អាន ដែលមានមន្ទីរស្ថិតនៅចម្ងាយតែ ១ គីឡូម៉ែតប៉ុណ្ណោះក្នុងឃុំតែមួយ[20]។ ជារឿយៗ អោ អាន បានទៅមើល វត្តតាមាក់ និងបានបើកវគ្គបណ្តុះបណ្តាល ឬសិក្សានយោបាយសម្រាប់កម្មាភិបាលនៅទីតាំង

[16] **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ត្រង់ A11, A15 [រៀបរាប់អំពីការចាប់ខ្លួនកម្មាភិបាលតំបន់ ដែលត្រូវបានបញ្ជូនទៅកាន់ វត្តតាមាក់ និងការប្រកាសរបស់ អោ អាន ថា កម្មាភិបាលចាស់ គឺជា "ជនក្បត់"។ **D219/315** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ ត្រង់ A152, A159-A163។ **D107/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ ERN ជាភាសាអង់គ្លេស 00787219-20 [វត្តតាមាក់ត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខក្រោយពេលការមកដល់របស់ អោ អាន]។ **D219/171** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ ត្រង់ A16។ **D219/288** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹន ឡៃស៊ីម ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ត្រង់ A39។ **D1.3.11.7** បទសម្ភាសរបស់ កសព ជាមួយ ចេង គុល និងគុណ សុខា ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៨ ត្រង់ ERN ជាភាសាអង់គ្លេស 00210439។ **D1.3.11.26** បទសម្ភាសរបស់ កសព ជាមួយ គុន សុថា ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៦ ត្រង់ ERN ជាភាសាអង់គ្លេស 00208384។

[17] **D219/331** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផន សុផល ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ត្រង់ A60-A63។

[18] **D219/315** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ត្រង់ A141-A142, A154-A164 [អតីតប្រធានភស្តុភារតំបន់រៀបរាប់ថាបានឃើញមនុស្ស៣០០នាក់ ត្រូវបានដឹកតាមឡានទៅកាន់វត្តតាមាក់]។

[19] **D219/376** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ ត្រង់ ERN ជាភាសាអង់គ្លេស 01111627។

[20] **D219/327** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង គុល ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ត្រង់ A5។

នោះ[21]។ នៅក្នុងការប្រជុំទាំងនោះ អោ អាន បានចាក់ខ្សែរអាត់សម្លេងនានាអំពី "ខ្មាំង"[22] និងបានប្រកាសថានឹងមាន "ការស្លាប់ច្រើន" ក្នុងតំបន់[23]។ ក្នុងនាមជាលេខាតំបន់ និងជាអនុលេខាភូមិភាគកណ្តាល គាត់ទទួលខុសត្រូវចំពោះការសម្រេចចិត្តលើជោគវាសនារបស់អ្នកដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅវត្តតាមាក់[24]។

៧. សពអ មានមូលហេតុឲ្យជឿបានថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើ រួមបង្កើតឲ្យមានឧក្រិដ្ឋកម្មនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ រួមមាន តែមិនកំហិតត្រឹមប៉ុណ្ណឹងទេ៖

ក. ការធ្វើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឲ្យទៅជាទាសករ, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមបង្កើតបានជា **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា ៥, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ អ.វ.ត.ក និង

ខ. មនុស្សឃាត និងទារុណកម្ម ជាការរំលោភ **ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦** (មាត្រា ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨) ដែលត្រូវផ្តន្ទាទោសតាមមាត្រា៣(ថ្មី), ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ អ.វ.ត.ក។

---

[21] **D219/376** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ ត្រង់ ERN ជាភាសាអង់គ្លេស 01111626-27។ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ត្រង់ A6។

[22] **D219/376** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ ត្រង់ ERN ជាភាសាអង់គ្លេស 01111627។

[23] **D219/376** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ ត្រង់ ERN ជាភាសាអង់គ្លេស 01111626-27។ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ត្រង់ A6។

[24] **D1.3.19.1** សេចក្តីណែនាំរបស់ ប.ក.ក មានចំណងជើងថា "សេចក្តីសំរេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ត្រង់ ERN ជាភាសាអង់គ្លេស 00182809 [ផ្តល់ឲ្យអចិន្ត្រៃយ៍ភាគទូវ "សិទ្ធិសំរេចកំទេចក្នុងជួរ និងក្រៅជួរ"]។

៨. សពអ មានមូលហេតុឲ្យជឿបានថា **យឹម ទិត ហៅ តាទិត, អោ អាន ហៅ តាអាន, អ៊ឹម ចែម** និងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដទៃទៀត រួមទាំង **នួន ជា** និង **ខៀវ សំផន** បានប្រព្រឹត្តអំពើព្រហ្មទណ្ឌជាក់លាក់ ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ជាបទល្មើសមានចែងក្នុងច្បាប់ អ.វ.ត.ក។ អំពើទាំងនេះគឺជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួម ដូចមានចែងក្នុងកថាខណ្ឌ២១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ [25] និងកថាខណ្ឌ ១៦ ដល់ ១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី។

៩. ដីកាសន្និដ្ឋាននេះត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់គត់ អាស្រ័យហេតុនេះ ដីកាសន្និដ្ឋាននេះត្រូវធ្វើឡើងតាមវិធាន៧១(៣) នៃវិធានផ្ទៃក្នុង។ កំណត់ហេតុនៃការខ្វែងយោបល់គ្នានេះ ត្រូវបានដាក់នៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដែលបានរក្សាទុកដោយក្រឡាបញ្ជីសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១(១) នៃវិធានផ្ទៃក្នុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[25] **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១។